**រដ្ឋាភិបាលជាតិខ្មែរនិរទេស**

**ជាតិ សាសនា ប្រជាជាតិខ្មែរ**

លេខៈ ០៧/១៦ រ.ជ.ខ.ន.

# សេចក្ដីថ្លែងការណ៍

**រដ្ឋាភិបាលជាតិខ្មែរនិរទេស** សូមប្រកាសថ្កោលទោសយ៉ាងដាច់អហង្ការចំពោះការឈ្លានពានរបស់ប្រទេសវៀតណាម និងគណបក្សនយោបាយណាដែលគាំទ្រគ្នា និងសហការជាមួយប្រទេសវៀតណាម ក្នុងការកែប្រែផែនទីបោន (Bonne) ខ្នាត ១/១០០.០០០ (មួយលើមួយរយពាន់) មកជាផែនទី យូ.ធី.អឹម (UTM) ខ្នាត ១/៥០.០០០ (មួយលើហាសិបពាន់)។

**រដ្ឋាភិបាលជាតិខ្មែរនិរទេស** មិនទទួលស្គាល់ចំពោះការកែប្រែផែនទីបោន(Bonne) ដែលបានធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ និងទទួលស្គាល់ដោយអន្តរជាតិចន្លោះឆ្នាំ១៩៦៣-១៩៦៩ ព្រមទាំងមិនទទួលស្គាល់ការចុះហត្ថលេខាលើសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងការបោះបង្គោលព្រំដែនថ្មីណា ដែលផ្ទុយនិងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ករណីដែលប្រទេសវៀតណាម និងរបបផ្ដាច់ការលោក ហ៊ុន សែន ដែលគាំទ្រដោយគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី ចង់កែប្រែខ្នាតផែនទីច្បាប់ដើម មកជាខ្នាតយូ.ធី.អឹម (UTM) ខ្នាត ១/៥០.០០០ (មួយលើហាសិបពាន់) វិញនោះ គឺជាការរំលោភលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស១៩៩១ ដែលធ្វើឱ្យបាត់បង់ទឹកដីខ្មែរទៅប្រទេសវៀតណាម និងរំលោភលើអធិប្បតេយ្យភាពជាតិខ្មែរ ដោយសារការកែប្រែខ្នាតផែនទីថ្មីនេះ។

**រដ្ឋាភិបាលជាតិខ្មែរនិរទេស** សូមអំពាវនាវដល់ប្រទេសបារាំង សហគមន៍អន្តរជាតិ និងជាពិសេសអង្គការសហប្រជាជាតិ សូមកុំចូលរួមនិងទទួលស្គាល់នូវការផ្លាស់ប្ដូរផែនទីថ្មីនេះ ព្រោះការផ្លាស់ប្ដូរផែនទីនេះ គឺខុសនឹងច្បាប់ដើមដែលទទួលស្គាល់ដោយអន្តរជាតិ និងអង្គការសហប្រជាជាតិចន្លោះឆ្នាំ១៩៦៣-១៩៦៩ ។

ធ្វើនៅប្រទេសដាណឺម៉ាក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម សេរី**

ទីស្នាក់ការកណ្ដាលបណ្ដោះអាសន្នរបស់ រ.ជ.ខ.ន., ប្រអប់សំបុត្រលេខ ៣៣៩០, ហ៊ុនិស្ទីល ប្រទេសដាណឺម៉ាក
Temporary Headquarter of K.N.G.E: P.O. Box 3390, Hundested, Denmark
Tel: (+45) 7184 8379; E-mail: primeministeroffice2016@gmail.com, website: www.kngexile.org